# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
លេខ ....២៤៨.................... ក.ប /ប្រ.ក

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣

# ប្រកាស
## ស្តីពី
## យន្តការទទួលពាក្យបណ្តឹងពលករទេសន្តរប្រវេសន៍

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-បានឃើញអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-បានឃើញអនុក្រឹត្យលេខ១៩០ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន

-តាមការចាំបាច់របស់ក្រសួង

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

## សម្រេច

**ប្រការ១.-**

ផ្នែកទទួល និងដោះស្រាយបណ្ដឹងតវ៉ាទាក់ទងនឹងពលករទេសន្តរប្រវេសន៍ ត្រូវបានបង្កើតឡើងនៅក្នុងនាយកដ្ឋានមុខរបរ និងហត្ថពលកម្មនៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្ត។

នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម និងមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្ត អាចអញ្ជើញដៃគូពាក់ព័ន្ធចូលរួមសហការផ្ដល់យោបល់ សម្រាប់ដោះស្រាយ សម្រុះសម្រួល ឬបញ្ជូនបណ្ដឹងតវ៉ាទៅស្ថាប័នមានភារកិច្ចស្របទៅតាមករណីចាំបាច់នីមួយៗ។

**ប្រការ២.-**

នៅព្រះរាជាណាចក្រកម្ពុជា រាល់បណ្ដឹងតវ៉ាទាក់ទងនឹងពលករទេសន្តរប្រវេសន៍ត្រូវដាក់នៅនាយកដ្ឋានមុខរបរ និងហត្ថពលកម្មនៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ស្ថិតនៅអគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឬនៅមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្តនីមួយៗ។

**ប្រការ៣.-**

បណ្ដឹងតវ៉ាទាក់ទងនឹងពលករទេសន្តរប្រវេសន៍អាចជាបណ្ដឹងផ្ទាល់មាត់ ឬតាមមធ្យោបាយផ្សេងៗឬត្រូវធ្វើជាលាយលក្ខអក្សរស្របតាមច្បាប់ បទបញ្ញា និងនីតិវិធីជាធរមាន។ ខ្លឹមសារនៃពាក្យបណ្ដឹងត្រូវរួមមានចំណុចសំខាន់ៗដូចខាងក្រោម៖

-កម្មវត្ថុនៃពាក្យបណ្ដឹង

-ឈ្មោះ និងអាសយដ្ឋានរបស់ដើមបណ្ដឹង

-ឈ្មោះ និងអាសយដ្ឋានរបស់ចុងចម្លើយ

-មូលហេតុ និងសាវតានៃពាក្យបណ្ដឹង

-កាលបរិច្ឆេទ និងទីកន្លែងនៃករណី

-ចំនួនប្រាក់ដែលទាមទារឲ្យសង (ប្រសិនបើមាន)

រាល់ពាក្យបណ្ដឹងត្រូវមានឯកសារគាំទ្រ និងលិខិតបញ្ជាក់ផ្សេងៗ (ប្រសិនបើមាន)។

**ប្រការ៤.-**

ក្រោយពីទទួលបានពាក្យបណ្តឹង ជាលាយលក្ខអក្សរ ក្នុងរយៈពេលមិនលើស ពី១០ថ្ងៃនៃថ្ងៃធ្វើការ នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តនីមួយៗត្រូវចាត់ការដោះស្រាយករណីនីមួយៗទៅតាមនីតិវិធី ដោយត្រូវធ្វើលិខិតអញ្ជើញភាគីវិវាទនីមួយៗមកផ្តល់ព័ត៌មាន និងឯកសារជាភស្តុតាងនានា ទៅតាមការចាំបាច់ និងដោះស្រាយវិវាទឲ្យបានសមស្រប។

រាល់ពាក្យបណ្តឹងដែលមិនមែនជាលាយលក្ខអក្សរ នាយកដ្ឋានមុខរបរនិងហត្ថពលកម្ម ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ត្រូវចាត់ការដោះស្រាយជាបន្ទាន់ទៅតាមនីតិវិធី។

**ប្រការ៥.-**

ក្នុងករណីភាគីដើមបណ្តឹង ឬតំណាងនៃជននេះ ទទួលបានលិខិតអញ្ជើញហើយ មិនព្រមអញ្ជើញទៅផ្តល់ព័ត៌មានបន្ថែមជូននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត តាមការកំណត់ចំនួនពីរដង ដោយគ្មានការជូនដំណឹងអំពីមូលហេតុសមស្របទេនោះ បណ្តឹងនោះត្រូវបានចាត់ទុកជាមោឃៈ។

រយៈពេលជូនដំណឹងមួយលើកៗ មិនឲ្យលើសពី៣ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានលិខិតជូនដំណឹង។

ក្នុងករណីភាគីចុងចម្លើយ ឬតំណាងនៃជននេះ ទទួលបានលិខិតអញ្ជើញហើយ មិនព្រមចូលបង្ហាញខ្លួនតាមការកំណត់ ចំនួនពីរដង ដោយគ្មានការជូនដំណឹងអំពីមូលហេតុសមស្របទេនោះ រឿងវិវាទត្រូវបានចាត់ទុកថាមិនសះជា ហើយត្រូវចាត់ទុកថាភាគីចុងចម្លើយមានកំហុសដូចការចោទប្រកាន់។

មន្ត្រីដោះស្រាយវិវាទ ត្រូវជូនដំណឹងជាបន្ទាន់ទៅភាគីនីមួយៗ អំពីបណ្តឹងដែលត្រូវបានចាត់ទុកជាមោឃៈ ឬភាគីមានកំហុសដូចការចោទប្រកាន់។

ភាគីដើមបណ្តឹង ឬចុងចម្លើយ មានសិទ្ធិឆ្លើយតបជាចុងក្រោយមក នាយកដ្ឋានមុខរបរ និងហត្ថពលកម្មឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត មិនឲ្យលើសពី៣ថ្ងៃ ចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ហើយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងចាត់វិធានការទៅតាមនីតិវិធី។

**ប្រការ៦.-**

ក្នុងករណីមានការពឹងពាក់ពីគូភាគីវិវាទ តតីយជនអាចជួយអម ឬធ្វើជាតំណាងរបស់ភាគីនីមួយៗបាន។ តតីយជននោះ ត្រូវតែជាមនុស្សពេញវ័យហើយអាចមានសិទ្ធិសម្រេចកិច្ចការបានផង។

**ប្រការ៧.-**

រាល់ការដោះស្រាយវិវាទត្រូវមានកំណត់ហេតុបញ្ជាក់ឲ្យបានច្បាស់លាស់អំពីការយល់ព្រម ឬមិនយល់ព្រមសះជានឹងគ្នា។ កំណត់ហេតុនោះត្រូវចុះហត្ថលេខាដោយមន្ត្រីដោះស្រាយវិវាទដោយផ្ទាល់ និងភាគីវិវាទទាំងសងខាង។ កំណត់ហេតុនេះត្រូវចម្លងចែកជូនគ្រប់ភាគីវិវាទ។

**ប្រការ៨.-**

រាល់ការព្រមព្រៀង ដែលបានធ្វើនៅចំពោះមុខមន្ត្រីដោះស្រាយវិវាទនៃនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត គឺជាការព្រមព្រៀងដែលចងកាតព្វកិច្ចតាមផ្លូវច្បាប់។ រាល់កិច្ចព្រមព្រៀងដែលបានសះជា ឬមិនសះជា ត្រូវធ្វើឡើងនៅចំពោះមុខមន្ត្រីដោះស្រាយវិវាទ។

**ប្រការ៩.-**

ក្នុងករណីដែលមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ដោះស្រាយអស់លទ្ធភាព តែវិវាទនៅតែមិនសះជាក្នុងរយៈពេលមិនលើសពី២០ថ្ងៃនៃថ្ងៃធ្វើការ មន្ទីរការងារ និងបណ្តុះបណ្តាលជីវៈខេត្ត ត្រូវបញ្ជូនសំណុំរឿងនោះមកនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម ដើម្បីចាត់វិធានការ និងដោះស្រាយទៅតាមនីតិវិធីបន្តទៀត។

ក្នុងករណីដំណោះស្រាយវិវាទការងារនៅនាយកដ្ឋានមុខរបរ និងហត្ថពលកម្មមិនសះជា ក្នុងរយៈពេលយ៉ាងយូរ៣០ថ្ងៃនៃថ្ងៃធ្វើការ មន្ត្រីដោះស្រាយវិវាទនៃនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម ត្រូវប្រកាសប្រាប់ភាគីទាំងអស់ថា មិនអាចផ្សះផ្សាវិវាទបានហើយត្រូវបញ្ចូលសេចក្តីប្រកាសនេះក្នុងកំណត់ត្រាជាផ្លូវការ ដែលត្រូវចុះហត្ថលេខាដោយមន្ត្រីដោះស្រាយវិវាទ និងគូភាគីនៃវិវាទ។ មន្ត្រីដោះស្រាយវិវាទ ត្រូវជម្រាបទៅគូភាគីអំពីសិទ្ធិរបស់គូភាគីនីមួយៗ និងនីតិវិធីច្បាប់ជាធរមាន។

ក្នុងករណីវិវាទ ឬសំនុំរឿងដែលបានទទួល កើតឡើងនៅក្រៅប្រទេស រយៈពេលនៃការដោះស្រាយបញ្ហា អាចត្រូវបានពន្យារពេលទៅតាមស្ថានភាពជាក់ស្តែង នៃប្រទេសទទួល។

**ប្រការ១០.-**

នៅក្រៅប្រទេស ពាល់ពាក្យបណ្តឹងត្រូវតែដាក់នៅតំណាងអចិន្ត្រៃយ៍នៃទីភ្នាក់ងារជ្រើសរើសឯកជនប្រចាំនៅប្រទេសទទួលពលករ ស្ថានឯកអគ្គរាជទូត ឬស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសទទួលពលករ និងស្ថាប័នមានសមត្ថកិច្ចរបស់ប្រទេសនីមួយៗ។

តំណាងទីភ្នាក់ងារជ្រើសរើសឯកជនកម្ពុជាប្រចាំនៅប្រទេសទទួលពលករ ត្រូវសម្របសម្រួល និងជួយសាមីពលករក្នុងការដាក់ពាក្យបណ្តឹងឲ្យបានត្រឹមត្រូវ និងទាន់ពេលទៅតាមករណីនីមួយៗ នៅស្ថានឯកអគ្គរាជទូត ឬស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅប្រទេសទទួលពលករ និងស្ថាប័នមានសមត្ថកិច្ចរបស់ប្រទេសទទួលនីមួយៗ។

**ប្រការ១១.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ អគ្គាធិការនៃអគ្គាធិការដ្ឋាន អង្គភាពក្រោមចំណុះក្រសួង និងទីភ្នាក់ងារជ្រើសរើសឯកជន ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

***កន្លែងទទួល៖***

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*-ទីស្តីការគណៈរដ្ឋមន្ត្រី*
*-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ*
*-ក្រសួងមហាផ្ទៃ*
*-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
*-គ្រប់សាលារាជធានី និងខេត្ត*
*" ដើម្បីជូនជ្រាប់*
*-ដូចប្រការ១៧ " ដើម្បីអនុវត្ត*
*-ឯកសារ-កាលប្បវត្តិ*